ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

លេខ ៩១៦ក្រ៩ "ខ"

ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០

សំណុំរឿងព្រហ្មទណ្ឌលេខ ១៤១៦

ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០

សំណុំរឿងស៊ើបសួរលេខ៖ ១០២៤

ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០

សំណុំរឿងជំនុំជម្រះលេខ៖១៧៦៤

ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានជំនុំជម្រះជាសាធារណៈលើសំណុំរឿងព្រហ្មទណ្ឌនាថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០ ដោយមានសមាសភាពចូលរួមដូចតទៅ

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ១៤១៦ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ [redacted] ស៊ីនហ៊ី ហៅ ចយ ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះ ទីកន្លែងកំណើតភូ[redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅផ្ទះគ្មា[redacted] រាជធានីភ្នំពេញ (បច្ចុប្បន្នត្រូវបានឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ) ឪពុកឈ្មោះ [redacted] ឌី "ស" ម្តាយឈ្មោះ [redacted] ណារី "ស" នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៖ ២៥០១ "ង" ដ.ឃ.ដ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ។

ជាប់ចោទពីបទ៖ **ឃាតកម្ម (ប្រើកាំបិតផ្គាក់កាប់)** ប្រព្រឹត្តនៅចំណុចមុខផ្ទះគ្មានលេខ ផ្លូវបេតុង ភូមិក្រពើទ្រោម សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] កល្យាណ ភេទស្រី អាយុ៣៦ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិក្រពើទ្រោម សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

### អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ២០ និង ៤០ នាទី នៅចំណុចមុខផ្ទះគ្មានលេខ ផ្លូវបេតុង ភូមិក្រពើទ្រោម សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ មានករណី ឃាតកម្ម (ប្រើកាំបិតផ្គាក់កាប់) ដែលបង្កឡើងដោយ



Scanned with CamScanner

រករឿងខ្ញុំទេ ហើយខ្ញុំនៅឈរកណ្ដាល គោលបំណងឃាត់ពួកគេទាំង២នាក់ កុំឱ្យឈ្លោះគ្នា តែឈ្មោះ [redacted] ស៊ុនហ៊ី ក៏បានស្ទុះទៅដេញកាប់ឈ្មោះ [redacted] វិសាល ។ បន្ទាប់មកខ្ញុំងើបពីដួល ដើរទៅកន្លែងកើតហេតុដែលមានចំងាយប្រហែល ១០ម៉ែត្រ បានឃើញឈ្មោះ [redacted] វិសាល ដេកសន្លប់មិនដឹងខ្លួនក្នុងថ្លុកឈាម រួចក្រុមគ្រួសាររបស់ [redacted] វិសាល បានបញ្ជូនទៅមន្ទីរពេទ្យ ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ក្រោយពីបានដេញដោលរួចមក ឃើញថា ជនជាប់ចោទបានឆ្លើយសារភាពពីទោសកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តដូចការចោទប្រកាន់ពិតមែន ។ ហេតុដូច្នេះតំណាងអយ្យការសូមរក្សាដីកាសន្និដ្ឋានស្ពាពរទុកនៅដដែល និងសុំឱ្យចៅក្រមជំនុំជម្រះសម្រេចតាមច្បាប់ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា៖ កូនក្ដីខ្ញុំមិនដែលមានទោសពីមុនមកទេ ហើយកូនក្ដីខ្ញុំមានសតិមិនល្អដូចគេទេ ដូច្នេះសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណាអំពីស្ថានសម្រាលទោសដល់កូនក្ដីខ្ញុំ ចំពោះសំណងរដ្ឋប្បវេណីដែលដើមបណ្ដឹងទាមទារនោះសូមឱ្យក្រុមប្រឹក្សាពិចារណាផង ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ុនហ៊ី៖ មិនមានសំណូមពរអ្វីមកតុលាការនោះទេ ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

**ក្រោយពីបានពិនិត្យ និងពិចារណាការត្រឹមត្រូវតាមច្បាប់ហើយ**

**<u>យល់ឃើញថា</u>**

-កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ ពិតជាអំពើ ឃាតកម្ម (ប្រើកាំបិតផ្គាក់កាប់) ប្រព្រឹត្តនៅចំណុចមុខផ្ទះគ្មានលេខ ផ្លូវបេតុង ភូមិក្រពើទ្រោម សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ស៊ុនហ៊ី ហៅ ចយ បានយកកាំបិតផ្គាក់ដងឫស្សី កាប់ទៅលើជនរងគ្រោះចំនួន ៣កាំបិត បណ្ដាលឱ្យស្លាប់ពិតប្រាកដមែន ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ុនហ៊ី ហៅ ចយ បានឆ្លើយសារភាពថា៖ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ ជនរងគ្រោះបានរករឿងខ្លួនអត់ហេតុផល ហើយបានវ៉ៃខ្លួនចំក្បាលពោះចំនួន២ដៃ ធ្វើឱ្យខ្លួនខឹងបានទៅផ្ទះយកកាំបិតផ្គាក់មកកាប់ទៅលើជនរងគ្រោះចំនួន ៣កាំបិតបណ្ដាលឱ្យស្លាប់ភ្លាមៗនៅកន្លែងកើតហេតុតែម្ដង ។ តាមចម្លើយសារភាពនេះអាចឱ្យតុលាការជឿជាក់បាន ព្រោះមានភាពស៊ីសង្វាក់ជាមួយចម្លើយរបស់ដើមបណ្ដឹង សាក្សី នឹងភស្តុតាងអាចឱ្យតុលាការជឿជាក់បាន ។

-តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] កល្យាណ បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ខ្លួននៅផ្ទះ ហើយប្ដីខ្លួនចេញទៅក្រៅដើម្បីរកបត់ជើង មួយសន្ទុះក្រោយមកក៏លឺសំលេងស្រែកឮ [redacted] ស៊ុនហ៊ី យកកាំបិតផ្គាក់

បានប្រព្រឹត្តអំពើឃាតកម្មពិតមែន ។ ហេតុដូច្នេះតំណាងអយ្យការសូមរក្សាដីកាសន្និដ្ឋានស្ថាពរទុកនៅដដែល និងសុំឱ្យចៅក្រមជំនុំជម្រះសម្រេចតាមច្បាប់ តាមការសន្និដ្ឋាននេះមានមូលដ្ឋានគ្រប់គ្រាន់ គប្បីតុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានទោសថា៖ កូនក្ដីខ្លួនមិនដែលមានទោសពីមុនមកទេ ហើយកូនក្ដីខ្លួនមានសតិមិនល្អ សូមឱ្យតុលាការធ្វើការពិចារណាអំពីស្ថានសម្រាលទោស គប្បីតុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់ ។

**ហេតុដូច្នេះសម្រេច**

១/ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ស៊ុនហ៊ី ហៅ ចយ ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ១០ (ដប់) ឆ្នាំ ពីបទ ឃាតកម្ម (ប្រើកាំបិតផ្គាក់កាប់) ប្រព្រឹត្តនៅចំណុចមុខផ្ទះគ្មានលេខ ផ្លូវបេតុង ភូមិក្រពើទ្រោម សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

២/វត្ថុតាងរួមមាន៖ កាំបិតផ្គាក់ចំនួន ១ដើម រឹបអូស និងបំផ្លាញចោលតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី ។ បើកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា: [redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ៨កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**
[redacted]

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០
**ក្រឡាបញ្ជី**
[redacted]